35/7

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៥៧៥

ចុះថ្ងៃទី ២៨-០៣-២០០៧

**សាលក្រមព្រហ្មទណ្ឌ**

**លេខ: ២៨ (៥)**

**ចុះថ្ងៃទី ០៧-០៧-២០០៩**

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជំរះសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០៩ ដោយមានសមាសភាពជំនុំជំរះ ដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោ[redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក[redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៥ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០០៧ ដែលមានជនជាប់-ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅភូមិអណ្តូង ឃុំគោករកា ខណ្ឌដង្កោ ក្រុងភ្នំពេញ . ទីលំនៅបច្ចុប្បន្ននៅភូមិអណ្តូង ឃុំគោករកា ខណ្ឌដង្កោ ក្រុងភ្នំពេញ មុខរបរ រកស៊ី ឪពុកឈ្មោះ[redacted] ស) ម្តាយឈ្មោះ[redacted] រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការមាន .ដីកាបង្គាប់អោយឃុំខ្លួនលេខ ៨៧៧ អយក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៧។

ជាប់ចោទពីបទ : **ផ្តល់សក្ខីភាពក្លែង** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងបទ : **ក្លែងលិខិតឯកជន** ប្រព្រឹត្តិនៅរាជធានីភ្នំពេញ កាលថ្ងៃទី ០៧ ខែមិនា ឆ្នាំ ១៩៩៣ និងថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣. បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ៦០ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅភូមិកណ្តឹង ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ . ទីលំនៅសព្វថ្ងៃនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបរធ្វើស្រែ ។

-មេធាវីការពារសិទ្ធិ និងតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លោក [redacted]



Scanned by CamScanner

35/6

***ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:***

នៅឆ្នាំ ១៩៩៣ ឈ្មោះ [redacted] និងតូកនបានធ្វើកិច្ចសន្យាទិញ និងលក់ដីក្លែងក្លាយមួយ ដោយក្លែងស្នាមមេដៃ និងដាក់ឈ្មោះ [redacted] ថាបានលក់ដីដែលមានទីតាំងស្ថិតនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ទៅអោយឈ្មោះ [redacted] រួចហើយក៏យកលិខិតក្លែងនេះទៅធ្វើការប្តឹងផ្តល់នៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសុំដាច់ដីខាងលើពីម្ចាស់កម្មសិទ្ធិស្របច្បាប់ ហើយឈ្មោ[redacted]ងតូកនក៏បានយកមនុស្សជាបក្សពួករបស់គេម្នាក់អោយដើរតួជាឈ្មោះ [redacted]ដោយបានធ្វើការឆ្លើយបំផ្លើសការពិតនៅចំពោះមុខតុលាការថា ដីដែលមានទំហំ ២១១២៣ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ថាជាដីរបស់ឈ្មោះ [redacted]លក់ទៅអោយខ្លួនឈ្មោះ [redacted] ក្នុងតម្លៃ០.៥ ដុល្លារដែលមានសាក្សីដឹងឮ ។ ប៉ុន្តែតាមការពិតឈ្មោះ[redacted]មែនជាម្ចាស់ដីនោះទេ ហើយក៏មិនដែលបានធ្វើកិច្ចសន្យា ឬផ្តិតមេដៃក្នុងនាមជាអ្នកលក់ ឬជាសាក្សីនោះដែរ ហើយឈ្មោ[redacted]ទដែលស្គាល់ឈ្មោះ[redacted] នោះទេ ។ នៅថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០០៧ ឈ្មោះ[redacted]បានដាក់ពាក្យបណ្តឹងប្តឹងពីឈ្មោះ[redacted]និងតូកន ពីបទផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតកិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ១៩៩៣ និងលិខិតប្រគល់ប្រាក់ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣ មកសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ពាក្យបណ្តឹង ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០០៧ របស់ឈ្មោះ[redacted]

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ១៦០ អ.យ.ក ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៣៦១១ ត.ព្រ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

***នាពេលសវនាការ :***

-ជនជាប់ចោទឈ្មោះ [redacted]ដិសេធពុំព្រមឆ្លើយនូវសំណួរដែលចៅក្រម តំណាងអយ្យការ មេធាវីសួរ ប៉ុន្តែបានទទួលស្គាល់ការប្តឹងរបស់ដើមបណ្តឹងដែលប្តឹងមកលើខ្លួនគឺជាការពិត ហើយក៏ទទួលស្គាល់ផងដែរនូវចម្លើយរបស់ដើមបណ្តឹងបានឆ្លើយនៅដំណាក់កាលអយ្យការ ចៅក្រមស៊ើបសួរ គឺជាការពិតទាំងអស់ ។

-តាមរំលោភចម្លើយជនជាប់ចោទឈ្មោ[redacted]ទៅដំណាក់កាលចៅក្រមស៊ើបសួរថា : កាលពីក្នុងឆ្នាំ ១៩៩៣ ខ្លួនបានទិញដីមួយកន្លែងស្ថិតនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឬស្សីកែវ ក្រុងភ្នំពេញ មានទំហំជាង ១០ហិតតា ក្នុងមួយម៉ែត្រ ការ៉េតំលៃមួយដុល្លារអាមេរិក ទិញពីឈ្មោះ[redacted]ភេទប្រុស ពីមុនជាមេប៉ុស្តិ៍ភ្នំពេញថ្មី បន្ទាប់ពីទិញដីនេះមក ខ្លួនបានចិញ្ចឹមជ្រូកត្រី និងធ្វើស្រែនៅទីនោះរហូតមក ។ ហើយខ្លួនបានអោយឈ្មោះ[redacted]ជាអ្នករៀបដី អោយខ្លួនដោយបានទិញលក់ត្រឹមត្រូវតាមច្បាប់ ។ ចំពោះឈ្មោ[redacted] នេះខ្លួនមិនដែលស្គាល់ពីមុនមកទេ ព្រោះឈ្មោ[redacted]ជាអ្នករៀបចំអោយ ប៉ុន្តែស្នាមមេដៃនៅលើកិច្ចសន្យា

ទិញ និងលក់ដីចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៣ និងលិខិតប្រគល់ប្រាក់ផ្ដាច់ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣ រវាងរូបខ្លួន និងឈ្មោះ [redacted] ដែលមានឈ្មោ[redacted]ជាសាក្សីនោះគឺពិតជាស្នាមមេដៃរបស់ខ្លួនមែន ដីនេះរូបខ្លួនបានទិញចូល គ្នាជាមួយមិត្តភ័ក្រខ្លួនឈ្មោះ [redacted] ពេលនោះមិនបានដាក់ឈ្មោះគាត់ ដោយសារគាត់គ្មានអត្តសញ្ញាណប័ណ្ណ ។ កាលពីរូបខ្លួនដាក់ពាក្យបណ្ដឹងប្ដឹងទាមទារដីនេះពីឈ្មោ[redacted] រូបខ្លួនមិនបាននាំឈ្មោះ [redacted] ទៅអោយតុលាការសាកសួរបំភ្លឺទេ គឺគ្រាន់តែដាក់ឯកសារជូនតុលាការជាសំរាងតែប៉ុណ្ណោះ ។ រហូតដល់ បច្ចុប្បន្នរូបខ្លួនក៏មិនដែលស្គាល់មុខឈ្មោ[redacted]ទេ គឺមិនដែលស្គាល់គ្នាទាល់តែសោះ ចំពោះតុលាការសាកសួរសាក្សីឈ្មោះ [redacted]ជារឿងរបស់ចៅក្រម និងក្រឡាបញ្ជីតែប៉ុណ្ណោះ ខ្លួនមិនបានដឹងរឿងអ្វីទេ ។ ខ្លួនសូមបញ្ជាក់ថាលិខិតកិច្ចសន្យាទិញ និងលក់ដីចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ១៩៩៣ និងលិខិតប្រគល់ប្រាក់ផ្ដាច់ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣ ដែលមានស្នាមមេដៃឈ្មោះ [redacted] រូបខ្លួនពុំដឹងថាជាស្នាមមេដៃរបស់អ្នកណាទេ ព្រោះពុំបានផ្ដិតនៅចំពោះមុខខ្លួន គឺឈ្មោ[redacted]យកមកអោយខ្លួនផ្ដិតតាមក្រោយ ។ ដីនេះសព្វថ្ងៃខ្លួនបានយកទៅបញ្ចាំគេបាត់ហើយក្នុងតំលៃ ៣៧៥.០០០ ( សាមសិបប្រាំពីម៉ឺនប្រាំពាន់ ) ដុល្លាអាមេរិក អោយឈ្មោះ [redacted] ។ រូបខ្លួនទើបតែស្គាល់លោក[redacted]ទេគឺគាត់ជាអ្នកជូនរូបខ្លួនទៅយកដី នេះបញ្ចាំជាមួយឈ្មោះ [redacted] ។

-តាមអំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ថា : ពាក្យបណ្ដឹងដែលខ្លួនបានប្ដឹងលើឈ្មោះ [redacted] និងតួកន ពីបទផ្ដល់សក្ខីភាពក្លែងក្លាយ និងក្លែងលិខិតកិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ១៩៩៣ និងលិខិតប្រគល់ប្រាក់ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣ ចូលមកអយ្យការពីថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០០៧ ខ្លួនសុំរក្សាខ្លឹមសារ និងសំណូមពរទុកជាបានការទាំងស្រុង ។

-តាមអំណានចម្លើយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោ[redacted]ថា :ចំពោះពាក្យបណ្ដឹង ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០០៧ និងចំលើយបានឆ្លើយនៅអយ្យការអមតុលាការក្រុងភ្នំពេញកាលពីថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០០៧ របស់កូនក្ដីខ្លួនឈ្មោះ [redacted] ខ្លួនសូមទទួលស្គាល់មិនកែប្រែទេ ។ ខ្លួនសូមបដិសេធចោលនូវកិច្ចសន្យាទិញ និងលក់ដីចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៣ និងលិខិតប្រគល់ប្រាក់ផ្ដាច់ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣ រវាងឈ្មោះ [redacted] និងឈ្មោះ [redacted] នេះចោល ព្រោះថាកូនក្ដីរបស់ខ្លួនឈ្មោះ [redacted] គាត់មិនដែលបានធ្វើកិច្ចសន្យា ឬបានផ្ដិតមេដៃលើលិខិតទាំងនោះទេកន្លងមក ។ ចំពោះកំហោត់ហេតុសួរចម្លើយរបស់ឈ្មោ[redacted] ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៤ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ២២៨ ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ ២០០៤ ដែលមានលោក [redacted] ជាចៅក្រម និងលោ[redacted] ក្រឡាបញ្ជីនោះ ខ្លួនសូមបដិសេធចោល ព្រោះកូនក្ដីខ្លួនឈ្មោះ [redacted] មិនដែលត្រូវបានតុលាការកោះហៅចូលមកឆ្លើយនៅក្នុងសំណុំរឿងរដ្ឋប្បវេណីមួយនេះម្ដងណាឡើយ ។ ចំពោះសាលក្រមលេខ ១៤ "យេ" ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០០៤ ខ្លួនសូមបដិសេធចោល ។



Scanned by CamScanner

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា** : ឈ្មោះ [redacted] ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន តំណាងអយ្យការសូមដកលំការចោទប្រកាន់ទុកជាបានការដដែល ។ ចំណែកការស្នើសុំរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ ដែលស្នើសុំអោយតុលាការចាត់របៀបបង្វិលសំណុំរឿងនេះទៅអយ្យការដើម្បីចោទប្រកាន់លើតួកននោះ សូមអោយតុលាការសម្រេចតាមច្បាប់ ។

**-មេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា** : ទោះបីជនជាប់ចោទមិនព្រមឆ្លើយក៏ដោយនាពេលសវនាការនេះ ក៏ជនជាប់ចោទបានយល់ព្រមទទួលកំហុសដែលខ្លួនបានប្រព្រឹត្តដែរ ក្នុងនាមខ្ញុំជាមេធាវីតំណាង និងការពារសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណី សុំអោយតុលាការសម្រេចផ្តន្ទាទោសឈ្មោះនេះតាមច្បាប់ ហើយសូមអោយតុលាការចាត់របៀបបង្វិលសំណុំរឿងនេះទៅអយ្យការដើម្បីចោទរបកាន់លើតួកនព្រោះតួកនឡើងវិញ ។

-ជនជាប់ចោទបានសំដីចុងក្រោយថា : សូមអោយតុលាការសម្រេចតាមច្បាប់ ។

**សំអាងហេតុ**

ក្រោយពីបាន:

ស្តាប់ចម្លើយ និងអំណានចម្លើយរបស់ជនជាប់ចោទ

ស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី

ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

ពិនិត្យ ភស្តុតាង ឯកសារនានា

**ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ឃើញថា:**

-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ពីបទ ផ្តល់សក្ខីភាពក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង បទក្លែងលិខិតឯកជន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលថ្ងៃទី ០៧ ខែមិនា ឆ្នាំ ១៩៩៣ និងថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣. បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-នាពេលសវនាការ ជនជាប់ចោទឈ្មោះ [redacted] បដិសេធពុំព្រមឆ្លើយនូវសំណួរដែលចៅក្រម តំណាងអយ្យការ មេធាវីសួរ ប៉ុន្តែបានទទួលស្គាល់ការប្តឹងរបស់ដើមបណ្តឹង ដែលប្តឹងមកលើខ្លួន គឺជាការពិត ហើយក៏ទទួលស្គាល់ផងដែរនូវចម្លើយរបស់ដើមបណ្តឹងបានឆ្លើយនៅចំពោះមុខកាលអយ្យការ ចៅក្រមស៊ើបសួរ គឺជាការពិតទាំងអស់ ។



Scanned by CamScanner

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ឆ្លើយនៅចៅក្រមស៊ើបសួរថា ខ្លួនបានទិញដីមួយកន្លែងស្ថិតនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ពីឈ្មោះ [redacted] ដែលមានទំហំជាង ១០ ហិចតា ហើយក្នុងមួយម៉ែត្រការ៉េតម្លៃ ១ដុល្លារអាមេរិក ពីឈ្មោះ [redacted]ាមេឃុំស្តីទីភ្នំពេញថ្មី ចំពោះឈ្មោះ [redacted] ខ្លួនពុំបានស្គាល់ទេ តែស្នាមមេដៃរវាងឈ្មោះ [redacted] និងរូបខ្លួនព្រមទាំងឈ្មោះ [redacted] ជាសាក្សីនោះគឺពិតជាស្នាមមេដៃរបស់ខ្លួនពិតមែន ចំពោះលិខិតកិច្ចសន្យាទិញ និងលក់ដីចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ១៩៩៣ និងលិខិតប្រគល់ប្រាក់ផ្តាច់ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣ ដែលមានស្នាមមេដៃឈ្មោះ [redacted] និងរូបខ្លួនពុំដឹងថាជាស្នាមមេដៃរបស់អ្នកណានោះទេ ព្រោះពុំបានផ្តិតនៅចំពោះមុខខ្លួននោះឡើយ គឺឈ្មោះ [redacted] យកមកអោយខ្លួនផ្តិតតាមក្រោយ ចម្លើយនេះពុំមានលក្ខណៈសមស្របឡើយ ដោយហេតុថាជនជាប់ចោទឈ្មោះ [redacted] ពុំមានភស្តុតាងបញ្ជាក់ឡើយ គ្រាន់តែជាការអះអាងដោយខ្លួនឯងតែប៉ុណ្ណោះ ហើយក៏ផ្ទុយទៅនឹងចម្លើយរបស់ឈ្មោះ [redacted] ដែលបានឆ្លើយថា ខ្លួនពុំមែនជាម្ចាស់ដីនោះទេ ហើយក៏មិនដែលបានធ្វើកិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ១៩៩៣ និងលិខិតប្រគល់ប្រាក់ផ្តាច់ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣ នោះដែរ ។

-តាមចំលើយរបស់ឈ្មោះ [redacted]ាមេធាវីតំណាងឈ្មោះ [redacted] និងឈ្មោះ [redacted] ឆ្លើយថា ខ្លួនសូមមិនទទួលស្គាល់នូវកិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ១៩៩៣ និងលិខិតប្រគល់ប្រាក់ផ្តាច់ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣ រវាងឈ្មោះ [redacted]ងឈ្មោះ [redacted] ឈ្មោះ [redacted] មិនដែលបានធ្វើកិច្ចសន្យា ឬបានផ្តិតមេដៃលើលិខិតទាំងនោះទេកន្លងមក ចំណែកកំណត់ហេតុសួរចម្លើយរបស់ឈ្មោះ [redacted] ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៤ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ២២៨ ចុះ ថ្ងៃទី ០២ ខែមីនា ឆ្នាំ ២០០៤ ដែលមានលោក [redacted] ជាចៅក្រម និងលោក [redacted] ជាក្រឡាបញ្ជីនោះ ឈ្មោះ [redacted] មិនដែលបានត្រូវតុលាការកោះហៅចូលមកឆ្លើយនៅក្នុងសំណុំរឿងរដ្ឋប្បវេណីមុននេះម្តងណាឡើយ ។ ចំពោះសាលក្រមលេខ ១៤ "ឈ" ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០០៤ ខ្លួនសូមបដិសេធ ។

-តាមការប្រកាសលទ្ធផលកោសល្យវិច្ច័យ ចុះថ្ងៃទី ០២ ខែមករា ឆ្នាំ ២០០៧ របស់ការិយាល័យកោសល្យវិច្ច័យទូទៅនៃនាយកដ្ឋាននគរបាលបច្ចេកទេស វិទ្យាសាស្ត្រ ក្រសួងមហាផ្ទៃ បញ្ជាក់ឱ្យឃើញថាស្នាមក្រយៅដៃលើកំណត់ហេតុយកចម្លើយ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៤ និងស្នាមមេដៃឈ្មោះ [redacted]លើកំណត់ហេតុយកចម្លើយ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០០៦ មិនដូចគ្នាឡើយ ។

-តាមចម្លើយរបស់ឈ្មោះ [redacted] ជាមេធាវីតំណាងឈ្មោះ [redacted] ចម្លើយដើមបណ្តឹងឈ្មោះ [redacted].ចម្លើយជនជាប់ចោទនាពេលសវនាការ និងភស្តុតាង ឯកសារនានា បញ្ជាក់អោយឃើញថាជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើផ្តល់សក្ខីភាពក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៩៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងបទក្លែងលិខិតឯកជន ប្រព្រឹត្តិនៅរាជធានីភ្នំពេញ កាលថ្ងៃទី ០៧



Scanned by CamScanner

25/2

ខែមិនា ឆ្នាំ ១៩៩៣ និងថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣ . បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូចការចោទប្រកាន់របស់តំណាងអយ្យការពិតប្រាកដមែន ។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ពីបទ : ក្លែងលិខិតឯកជន ប្រព្រឹត្តិទៅរាជធានីភ្នំពេញ កាលថ្ងៃទី ០៧ ខែមិនា ឆ្នាំ ១៩៩៣ និងថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣. បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង ពីបទ : ផ្តល់សក្ខីភាពក្លែង ប្រព្រឹត្តទៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០៤. បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] បានប៉ះពាល់ទៅលើសិទ្ធិ និងតួនាទីរបស់បុគ្គល ប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងប៉ះពាល់ទៅលើនីត្យានុកូលភាពសង្គមដែលច្បាប់បានការពារយ៉ាងម៉ឺងម៉ាត់បំផុត ។

-អំពើរបស់ជនជាប់ចោទ ប្រព្រឹត្តឡើងដោយមានស្មារតីទទួលខុសត្រូវគ្រប់គ្រាន់ ។

-ការលើកឡើងរបស់មេធាវីការពារសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណីក្នុងសេចក្តីសន្និដ្ឋានការពារ ដែលស្នើរសុំអោយតុលាការចាត់របៀបបង្វិលសំណុំរឿងនេះ ទៅអយ្យការដើម្បីចោទប្រកាន់លើគូកននោះ ឃើញថាពុំមានលក្ខណៈសមស្របឡើយ ដោយហេតុថា នៅដំណាក់កាលចៅក្រមស៊ើបសួរ តុលាការស្វែងរកសាវតាជាតិរបស់គូកនមិនឃើញឡើយ ហើយបានសម្រេចលើកលែងចោទប្រកាន់តាមដីកាលេខ ៦៤៧ តព្រ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៩ រួចហើយ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានចូលខ្លួនមកប្តឹងទាមទារសំណងជម្ងឺចិត្តអ្វីទេ គប្បីទុកសិទ្ធិអោយដើមបណ្តឹងប្តឹងទាមទារសំណងនៅពេលក្រោយ ។

## ហេតុដូច្នេះសំរេច

១-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០០០០០០ (ប្រាំលាន) រៀល ដាក់ចូលថវិការដ្ឋ ពីបទ :**ក្លែងលិខិតឯកជន** ប្រព្រឹត្តិទៅរាជធានីភ្នំពេញ កាលថ្ងៃទី ០៧ ខែមិនា ឆ្នាំ ១៩៩៣ និងថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៩៣ . បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១ (មួយ) ឆ្នាំ ពីបទ : **ផ្តល់សក្ខីភាពក្លែង** ប្រព្រឹត្តទៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល សរុបកំណត់ចំនួន ២ (ពីរ) ឆ្នាំ គិតបន្តពីសាលក្រមមុន ។ ✓

២-បង្គាប់អោយឈ្មោះ [redacted] បង់ប្រាក់ពិន័យចំនួន ៥០០០០០០ (ប្រាំលាន) រៀល ដាក់ចូលថវិការដ្ឋ ពីបទ : **ក្លែងលិខិតឯកជន** ប្រព្រឹត្តិទៅរាជធានីភ្នំពេញ កាលថ្ងៃទី ០៧ ខែមិនា ឆ្នាំ ១៩៩៣ និងថ្ងៃទី ១០



Scanned by CamScanner

35/1

ខែមេសា ឆ្នាំ១៩៩៣ . បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្ដន្ទាទោសតាមមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។

៣-បដិសេធចោលការសុំចាត់របៀបបង្វិលសំណុំរឿងនេះទៅរយក្សការ ដើម្បីចោទប្រកាន់លើតួករបស់មេធាវីតំណាង និងការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណី ។

៤-ទុកសិទ្ធិអោយដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទាមទារសំណងនៅពេលក្រោយ ។

៥-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០០៩ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ។

បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជំរះ**

ហត្ថលេខា និងត្រា : [redacted] | ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**

**ចៅក្រមជំនុំជំរះ**

[redacted]

( បានចម្លងត្រឹមត្រូវតាមច្បាប់ដើម )

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០០៩

**ក្រឡាបញ្ជី**

[redacted]



Scanned by CamScanner